**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

# លិខិតរំលែកមរណទុក្ខ

## សូមគោរពជូន

## លោកជំទាវ សម លក្ខិណា និងក្រុមគ្រួសារ ចំពោះមរណភាព ឯកឧត្តមសន្តិបណ្ឌិត ឌុល គឿន សមាជិកសភាតំណាងរាស្ត្រមណ្ឌលខេត្តកណ្ដាល

លោកជំទាវនិងក្រុមគ្រួសារជាទីរាប់អាន!

ខ្ញុំនិងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្តីសោកស្ដាយជាពន់ពេកក្រោយពីបានទទួលដំណឹងថា ឯកឧត្តមសន្តិបណ្ឌិត ឌុល គឿន សមាជិកសភាតំណាងរាស្ត្រមណ្ឌលខេត្តកណ្ដាល បានទទួលមរណភាពកាលពីថ្ងៃអាទិត្យ ១៥ កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ១៨:១២ នាទី ក្នុងជន្មាយុ ៧៤ ឆ្នាំ ដោយជរាពាធ។

ក្នុងវេលាពោរពេញដោយក្ដីរំជួលចិត្តនិងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំនិងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្តែងនូវសេចក្តីសោកស្តាយស្រណោះ អាឡោះអាល័យជាទីបំផុត ចំពោះមរណភាពរបស់ ឯកឧត្តមសន្តិបណ្ឌិត ឌុល គឿន ដែលជាការបាត់បង់នូវស្វាមី ឪពុក ឪពុកក្មេក និងជីតាជាទីស្រឡាញ់ដ៏ឧត្តុង្គឧត្តម ប្រកបដោយព្រហ្មវិហារធម៌។ មរណភាពរបស់ ឯកឧត្តមសន្តិបណ្ឌិត ឌុល គឿន គឺជាការបាត់បង់យ៉ាងធំធេងនូវវត្ស្សរជន ជាថ្នាក់ដឹកនាំជាន់ខ្ពស់មួយរូប ធ្លាប់បានធ្វើពលិកម្មក្នុងបុព្វហេតុ ជាតិ សាសនា និងព្រះមហាក្សត្រ តាមរយៈការចូលរួមចំណែកក្នុងកិច្ចការអភិវឌ្ឍប្រទេសជាតិចាប់តាំងពីក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ មក។

ក្នុងបរិយាកាសដ៏ក្រៀមក្រំបំផុតនេះ យើងខ្ញុំទាំងអស់គ្នា សូមឧទ្ទិសបបួងសួងជូនវិញ្ញាណក្ខន្ធ ឯកឧត្តមសន្តិបណ្ឌិត ឌុល គឿន សូមអញ្ជើញទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម លោកជំទាវ ព្រមទាំងក្រុមគ្រួសារ មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំទាំងអស់គ្នា៕

ថ្ងៃ ចន្ទ ១ រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០២២
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ**
រដ្ឋមន្ត្រី

ព្រុំ សុខា